# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យចូលឆ្នាំខ្មែរ
# ផ្សារតូច ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៩
# ឲ្យយើងយកចិត្តទុកដាក់ដោយទទួលស្គាល់តម្លៃនៃជីវិត

**អត្ថបទទី១៖ យេរេមី ៣១,១០-១៣**

ប្រជាជាតិទាំងឡាយអើយ ចូរនាំគ្នាស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយផ្សព្វផ្សាយរហូតដល់កោះឆ្ងាយៗ។ យរ ៣១,១០

**ដំណឹងល្អ៖ យ៉ូហាន ១១,៤៥-៥៧**

គេរកព្រះយេស៊ូ ហើយនិយាយគ្នាទៅវិញទៅមកក្នុងព្រះវិហារថា៖ «អ្នកគិតដូចម្ដេច? លោកមិនហ៊ានមកចូលរួមក្នុងពិធីបុណ្យទេមើលទៅ!»។ យហ ១១,៥៦

បងប្អូនជាទីស្រឡាញ់!

ជំនឿរបស់យើង ជីវិតរបស់យើងធ្វើដំណើរជាមួយគ្នា ខ្ញុំជាគ្រីស្តបរិស័ទរស់នៅប្រទេសកម្ពុជាខ្ញុំជាគ្រីស្តបរិស័ទជនជាតិខ្មែរ ខ្ញុំធ្វើយ៉ាងម៉េចឲ្យខ្ញុំចូលព្រះវិហារមុនគេបង្អស់ មុនទៅដើរលេង មុខទៅសួរសុខទុក្ខគេ ខ្ញុំចូលសួរសុខទុក្ខព្រះជាម្ចាស់ដើម្បីឲ្យព្រះជាម្ចាស់ប្រទានព្រះពរ។ ដូចយើងបានស្ដាប់នៅក្នុងទំនុកតម្កើងអម្បាញមិញ "**សូមទ្រង់ប្រទានពរឲ្យយើង និងមនុស្សទាំងពួងគ្រប់អាត្មា ទាំងអ្នករស់នៅឆ្ងាយផងណា មនុស្សលើលោកា ខ្លាចព្រះអង្គ**" នេះជាព្រះពរដែលយើងបានទទួលពីព្រះជាម្ចាស់។ នេះជាពាក្យទូលអង្វររបស់យើង នៅថ្ងៃនេះយើងចូលនៅក្នុងវិហារ ដោយសារយើងជាគ្រីស្តបរិស័ទដែលជាជនជាតិខ្មែរក្ដី ជាជនបរទេសដែលរស់នៅលើទឹកដីកម្ពុជាក្ដី ដើម្បីចូលនៅក្នុងអំណរសប្បាយរបស់ប្រទេសទាំងមូល និងដើម្បីទូលអង្វរព្រះអង្គឲ្យព្រះអង្គប្រទានពរសម្រាប់ខ្ញុំដែលជាគ្រីស្តបរិស័ទ សម្រាប់គ្រួសាររបស់ខ្ញុំ សម្រាប់ព្រះសហគមន៍កាតូលិករបស់ខ្ញុំដែលស្ថិតនៅក្នុងប្រទសកម្ពុជា និងសម្រាប់បងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទផងដែរ។ យើងជឿថា ព្រះជាម្ចាស់បានបង្កើតយើងទាំងអស់គ្នា ព្រះជាម្ចាស់ស្រឡាញ់យើងទាំងអស់គ្នា និងព្រះជាម្ចាស់ចង់ឲ្យយើងទទួលសុភមង្គលទាំងអស់គ្នា។ ដូច្នេះ ថ្ងៃនេះជាថ្ងៃសំខាន់ណាស់សម្រាប់យើងដែលជាគ្រីស្តបរិស័ទ ដោយសារព្រះជាម្ចាស់ផ្ទាល់ដែលប្រទានពរឲ្យយើង ដើម្បីឲ្យយើងមានកម្លាំងថ្មី ដើម្បីឲ្យយើងមានជំនឿរឹងមាំ ដើម្បីឲ្យយើងពោរពេញដោយសេចក្ដីស្រឡាញ់នៅក្នុងជីវិតយើងប្រចាំថ្ងៃ និងដើម្បីឲ្យយើងមានសមត្ថភាពជូនពរដល់បងប្អូនឯទៀតៗ។

ពេលយើងថ្វាយអភិបូជា យើងមានពេលវេលាដើម្បីចែកសេចក្ដីសុខសាន្ត ដែលជាសេចក្ដីសុខសាន្តចេញពីគុអាសនៈ ចេញពីតុសក្ការៈ ចេញពីព្រះយេស៊ូផ្ទាល់ គឺព្រះយេស៊ូផ្ទាល់

ដែលណែនាំឲ្យយើងទទួលសេចក្តីសុខរបស់ព្រះអង្គ ក្រោយមកយើងជូនសេចក្តីសុខឲ្យគ្នាទៅវិញទៅមក។ ប្រភពនៃសេចក្តីសុខសាន្តនេះ មិនមែនមកពីខ្ញុំញញឹម មិនមែនមកពីខ្ញុំលើកដៃប្រណម ប៉ុន្តែមកពីព្រះយេស៊ូផ្ទាល់ដែលនៅលើតុសក្ការៈដែលទៅជាព្រះកាយ និងទៅជាព្រះលោហិតព្រះគ្រីស្ត។ នៅក្នុងអភិបូជានេះ យើងទទួលព្រះពរពីព្រះជាម្ចាស់ផ្ទាល់ដើម្បីនៅបីថ្ងៃខាងមុខនេះ យើងអាចទៅជូនពរដែលមកពីព្រះជាម្ចាស់ដល់បងបប្អូនឯទៀតៗ។

ថ្ងៃនេះខ្ញុំចង់ឲ្យបងប្អូនគិតពិចារណា នៅពេលដែលយើងចេញពីព្រះវិហារនេះ **តើខ្ញុំមានពាក្យជូនពរអ្វីខ្លះដល់បងប្អូនឯទៀតៗ? តើខ្ញុំមានពាក្យជូនពរអ្វីខ្លះដល់ក្រុមគ្រួសារខ្ញុំ? តើខ្ញុំមានពាក្យជូនពរអ្វីខ្លះដើម្បីឲ្យព្រះសហគមន៍ខ្ញុំទៅមុខជាមួយព្រះជាម្ចាស់? តើខ្ញុំមានពាក្យជូនពរអ្វីខ្លះដល់សត្រូវរបស់ខ្ញុំ? តើខ្ញុំមានពាក្យជូនពរអ្វីខ្លះដល់មនុស្សប៉ុន្មានអ្នកក្នុងរយៈពេលមួយឆ្នាំកន្លងមកខ្ញុំបានមើលងាយ និងនិយាយដើមគេ?** ដូច្នេះឲ្យយើងគិតទៅ កុំឲ្យយើងចេញពីព្រះវិហារដោយទទួលទឹកព្រះពរនិងបន្តដើរលេងសប្បាយៗ ឲ្យយើងគិតពិចារណានៅពេលខ្ញុំទៅជួបបងប្អូនពេលខ្ញុំទៅជួបសត្រូវខ្ញុំ ពេលខ្ញុំទៅជួបតាយាយឪពុកម្តាយខ្ញុំ ឬពួកម៉ាក់ខ្ញុំ **តើឆ្នាំនេះខ្ញុំជូនពរអ្វីខ្លះដល់គាត់?** ដោយដឹងថាពរនេះមកពីអភិបូជានេះ ពរនេះមកពីព្រះជាម្ចាស់ដែលប្រទានពរតាមអ្វីដែលយើងសុំ "**សូមទ្រង់ប្រទានពរឲ្យយើង នឹងមនុស្សទាំងពួងគ្រប់អាត្មា**"។

ប៉ុន្មានថ្ងៃមុន ខ្ញុំបានជួបក្រុមដែលមានមេរោគអេដស៍១០០គ្រួសារ ដោយបានសហការជាមួយមន្ទីរធម្មការនិងសាសនាខេត្តតាកែវ ជាមួយឥស្លាម ជាមួយពុទ្ធសាសនា។ អ្វីដែលសំខាន់នៅពេលខ្ញុំចែករំលែក លើកទឹកចិត្ត ជូនអំណោយខ្លះៗដល់បងប្អូនទាំងនោះរួមជាមួយតំណាងសាសនាឥស្លាម រួមជាមួយតំណាងព្រះពុទ្ធសាសនា រួមជាមួយប្រធានមន្ទីរធម្មការ រួមជាមួយព្រះសហគមន៍កាតូលិកយើង ដូចជាយើងរួមគ្នាសួរសុខទុក្ខដើម្បីបង្ហាញថា ជីវិតរបស់យើងជាអ្នកណាក៏ដោយមានតម្លៃណាស់។ យើងមិនអាចវិនិច្ឆ័យមនុស្សនៅលើរូបរាងគេ នៅលើជម្ងឺរបស់គេ គេជាជនពិការ គេជាអ្នកជំងឺ គេជាមនុស្សចាស់ក្មេង ជាគេអ្នកក្រ គេជាអ្នកមាន យើងមិនអាចវិនិច្ឆ័យមនុស្សនៅលើអ្វីដែលយើងមើលឃើញភ្លាមៗ។ យើងត្រូវការដឹងថា មនុស្សទាំងអស់មានតម្លៃថ្លៃថ្នូរ សម្រាប់មនុស្សទាំងអស់ដែលជាគ្រីស្តបរិស័ទ ដែលជាសាវ័ករបស់ព្រះយេស៊ូ ឲ្យយើងមើលរបៀបរបស់ព្រះយេស៊ូនៅក្នុងគម្ពីរដំណឹងល្អ របៀបដែលព្រះយេស៊ូបានធ្វើដំណើរពីមួយថ្ងៃទៅមួយថ្ងៃជាមួយមនុស្សគ្រប់ប្រភេទៗ ដើម្បីណែនាំឲ្យគេមានសុភមង្គល គេជាអ្នកមានបាប គេពោរពេញដោយការលំបាកព្រះយេស៊ូណែនាំឲ្យគេមានជីវិតថ្មី។ គេជាមនុស្សតូចតាច ព្រះយេស៊ូលើកតម្កើងគេឲ្យមានជីវិតដូចគេដូចឯង គេជាស្ត្រីដែលអស់សង្ឃឹមក្នុងជីវិត ព្រះយេស៊ូមិនវិនិច្ឆ័យកាត់ក្តីផ្ទុយទៅវិញព្រះយេស៊ូមានព្រះបន្ទូលថា "**ឥលូវនេះនាងបានទទួលជីវិតថ្មី ដូច្នេះឈប់ធ្វើ**

**អំពើបាបតទៅទៀត**"។ ឲ្យយើងមើលរបៀបរបស់ព្រះយេស៊ូ របៀបដែលចេះតែទទួលមនុស្សទាំងអស់ ដោយសារមនុស្សម្នាក់ៗជាតំណាងរបស់ព្រះជាម្ចាស់ដ៏ពេញលក្ខណៈ មនុស្សម្នាក់ៗពោរពេញដោយតម្លៃថ្លៃថ្នូរនៃជីវិត។ ក្នុងឆ្នាំថ្មីនេះ ឲ្យយើងបន្តយកចិត្តទុកដាក់មិនមែនតាមរយៈតែក្រុមសង្គហៈមេត្តាករុណាតែប៉ុណ្ណឹង ប៉ុន្តែយើងរៀងៗខ្លួនកន្លែងដែលយើងនៅ ន្លែងដែលយើងធ្វើការ កន្លែងដែលយើងមានជីវិតប្រចាំនៅក្នុងសង្គមបច្ចុប្បន្ននេះ បើកភ្នែកទៅដើម្បីណែនាំឲ្យតម្លៃថ្លៃថ្នូរនៃជីវិតទៅជាសេចក្តីពិតសម្រាប់មនុស្សទាំងអស់ ជាពិសេសសម្រាប់មនុស្សតូចតាចទុរគតដែលអស់សង្ឃឹមនៅក្នុងជីវិត។ យើងដឹងថាពិភពលោករបស់យើង អាចពោរពេញដោយសេចក្តីសុខសាន្តលុះត្រាតែយើងអាចទទួលស្គាល់ថា យើងទាំងអស់គ្នាយើងជាបងប្អូន យើងបង្កើតទំនាក់ទំនងនៅក្នុងបងប្អូនបង្កើតឲ្យយើងថែរក្សាភាតរភាពយ៉ាងច្បាស់លាស់។

នៅពេលខ្ញុំបានជូនពរយាយតាមួយចំនួនពីរថ្ងៃមុន ខ្ញុំឃើញយាយតាក្រីក្រដែលមកពីភូមិឆ្ងាយៗ គាត់សប្បាយចិត្តមកដើម្បីឲ្យក្មេងៗមុជទឹកឲ្យគាត់ ដោយដឹងថាទឹកនេះជាការគោរពរបស់ក្មេងៗចំពោះចាស់ៗ ជាក្មេងៗដែលបង្ហាញសេចក្តីស្រឡាញ់ចំពោះតាយាយ។ នៅព្រះសហគមន៍របស់យើង ឲ្យយើងធ្វើជាគំរូនៅក្នុងការបង្កើតទំនាក់ទំនងរវាងក្មេងៗនិងចាស់ទុំ រវាងជំនាន់ថ្មីៗដែលមានរបៀបប្លែកៗនឹងជំនាន់ចាស់ៗដែលមានរបៀបចាស់បុរាណ។ ឥលូវនេះយើងទទួលឥទ្ធិពលច្រើន បទចម្រៀង របៀបទំនាក់ទំនង របៀបស្លៀកពាក់ របៀបដាក់ពណ៌សក់...។ យើងធ្វើយ៉ាងម៉េច ដើម្បីឲ្យទាំងចាស់ៗយកចិត្តទុកដាក់អប់រំណែនាំក្មេងៗ ក្មេងៗយកចិត្តទុកដាក់ដើម្បីគោរពនឹងស្តាប់ពាក្យប្រៀនប្រដៅរបស់ចាស់ៗ។ យើងធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាគំរូមួយដោយចេះគោរពចាស់ៗ និងចាស់ៗចេះអប់រំក្មេងៗ ក្មេងៗចេះទទួលដើម្បីដើរតាមផ្លូវល្អ។ ទោះបីយើងមានរបៀបផ្សេង ទោះបីយើងមានសង្គមរបស់យើងដែលណែនាំឲ្យយើងមានអ្វីៗទាំងអស់ ប៉ុន្តែយើងដឹងថាសីលធម៌នៅក្នុងខ្លួនយើងមានការស្រឡាញ់អ្នកដទៃ ការស្រឡាញ់ផ្ទាល់ខ្លួន។ យើងត្រូវការធ្វើយ៉ាងម៉េច ដើម្បីឲ្យព្រះសហគមន៍មានសម្លេង ដើម្បីអប់រំយុវជនឲ្យគេដឹងពីក្មេងមកថាជីវិតមានតម្លៃណាស់ស្តាប់ចាស់ៗទៅ ចាស់ៗមានបទពិសោធន៍ ចាស់ៗមានគំនិត មានប្រាជ្ញាឈ្លាសវៃ។ ឲ្យជំនាន់នីមួយៗអាចធ្វើដំណើរជាមួយគ្នានិងចូលគ្នា ដើម្បីទទួលការអប់រំនិងទទួលការគោរព ដោយដឹងថាបទពិសោធន៍គឺសំខាន់និងណែនាំឲ្យយើងអាចមានស្មារតីនិងពន្លឺថ្មីសម្រាប់ជីវិតបច្ចុប្បន្ននេះ។

អ្វីដែលសំខាន់សម្រាប់យើង ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីយកចិត្តទុកដាក់នៅក្នុងការទទួលខុសត្រូវយើងផ្ទាល់ យើងនៅក្មេង យើងជានិស្សិត យើងជាគ្រូបង្រៀន យើងបងស្រី លោកឪពុកលោកអភិបាល យើងជាក្រុមចម្រៀង យើងជាក្រុមសង្គហៈ យើងជាក្រុមពិធីបុណ្យ យើងជាអ្វីក៏

ដោយ សំខាន់បំផុតយកចិត្តទុកដាក់អស់ពីសមត្ថភាព នៅក្នុងការទទួលខុសត្រូវរបស់យើង។ យើងមានតួនាទីផ្ទាល់ យើងមានការងារផ្ទាល់ យើងអ្វីដែលយើងត្រូវការទទួលនៅក្នុងព្រះសហគមន៍និងនៅក្នុងសង្គម ប៉ុន្តែសំខាន់បំផុតឲ្យយើងយកចិត្តទុកដាក់ទទួលខុសត្រូវអស់ពីសមត្ថភាព ទាំងព្រះសហគមន៍ទាំងសង្គមឲ្យទៅមុខនិងរីកចម្រើននៅក្នុងផ្លូវល្អ។ ឲ្យជីវិតរបស់យើង បន្តរស់នៅក្នុងពន្លឺយើងទទួលពីព្រះគ្រីស្ត។ យើងធ្វើយ៉ាងម៉េចដើម្បីឲ្យយើងផ្ទាល់ខ្លួនខ្ញុំបានទទួលតួនាទីមួយនៅក្នុងសង្គមបច្ចុប្បន្ននេះ ខ្ញុំទទួលខុសត្រូវជាន់ខ្ពស់នៅក្នុងការងារ នៅក្នុងតួនាទីរបស់ខ្ញុំ ជាពិសេសនៅក្នុងជីវិតខ្ញុំជាគ្រីស្តបរិស័ទ។ ឲ្យខ្ញុំទទួលខុសត្រូវអស់ពីសមត្ថភាពដើម្បីប្រកាសដំណឹងល្អ ដើម្បីធ្វើជាមេនៅក្នុងម្សៅនៃសង្គមនេះ ដើម្បីធ្វើជាពន្លឺយ៉ាងតូចនៅក្នុងសង្គម ដើម្បីធ្វើជាសសរមួយយ៉ាងពិសេស។ ត្រូវតែរស់នៅអស់ពីសមត្ថភាព តាមរបៀបដែលព្រះជាម្ចាស់បានរៀបចំសម្រាប់ខ្ញុំជាគ្រីស្តបរិស័ទ។ ខ្ញុំចង់ឲ្យឆ្នាំថ្មីនេះ យើងយកព្រះនាងម៉ារីធ្វើជាគំរូមួយពិសេស ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូ ដើម្បីស្រឡាញ់ព្រះយេស៊ូថែមទៀត។ ចុងក្រោយបំផុតជីវិតរបស់យើង រកឃើញអត្ថន័យ រកឃើញតម្លៃ រកឃើញកម្លាំង លុះត្រាតែយើងភ្ជាប់ជាមួយព្រះយេស៊ូដែលបំភ្លឺ ដែលណែនាំ ដែលលើកទឹកចិត្តយើងទាំងអស់គ្នា។

ទី១ ឲ្យយើងយកចិត្តទុកដាក់ដោយទទួលស្គាល់តម្លៃនៃជីវិត និងបង្កើតភាតរភាពរវាងគ្នានិងគ្នា ទី២ ឲ្យយើងចេះគោរពចាស់ទុំ ចេះគោរពគ្នាទៅវិញទៅមក និងស្តាប់ដើម្បីរីកចម្រើននៅក្នុងអន្តរជំនាន់ និងទី៣ ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីយកចិត្តទុកដាក់អស់ពីសមត្ថភាព នៅក្នុងការទទួលខុសត្រូវរបស់យើង នៅក្នុងគ្រប់វិស័យនៃជីវិត ជាពិសេសនៅក្នុងជីវិតយើងជាគ្រីស្តបរិស័ទ។ នៅក្នុងឆ្នាំថ្មីនេះ សូមព្រះជាម្ចាស់ប្រទានពរឲ្យយើងដើម្បីឲ្យឆ្នាំថ្មីនេះទៅជាឆ្នាំដែលប្រកបដោយសេចក្តីសុខសាន្ត និងដោយសុភមង្គលពិតប្រាកដ។ អាម៉ែន៕